# អ្នកហ៊ានស្លាប់ ក្លាយជាមិនស្លាប់

ដោយសារយួនយៀកមិញបានបញ្ចេញបំណងពិតរបស់គេឲ្យយើងឃើញច្បាស់ដូចនេះ យើងក៏បានចាត់ចែងការសព្វគ្រប់ដើម្បីទប់ទល់ ៗ ដំបូងយើងបានប្រជុំគ្នារើសអ្នកដឹកនាំចលនារបស់យើង ដោយមានលោកតា ថាច់ ហ៊ុម អាចារ្យវត្តពោធិព្រឹក្ស លោកតា ឡាំ ណុប គសិករនិងបងប្អូនយើងខ្លះទៀតចូលរួមផង ៗ មតិអង្គប្រជុំបានមូលមកលើចំដោយ ផាត់ ពីព្រោះជាកូនក្រោលបង្គោលស្និទ្ធស្រាប់ ៗ

បន្ទាប់មកទៀត យើងបានធ្វើការបញ្ជាក់ទៅលើខ្សែបន្ទាត់របស់ចលនាយើង ពីព្រោះយើងជាជនជាតិតិចនៅក្នុងកណ្ដាប់ដៃគេ ត្រូវឲ្យមានខ្សែបន្ទាត់ដែលមិនអាចនាំយើងទៅរកក្ដីវិនាសបានទៅថ្ងៃក្រោយ ៗ ក្រោយពីបានជជែកគ្នាមួយលើក ជាពីរលើកមក ទើបដើម្បីឲ្យមានការឯកភាពពីមជ្ឈដ្ឋានព្រះសង្ឃផង យើងក៏បាននិមន្តលោកតា ថាច់ -

ពេជ ទៅអធិការវត្តពោធិព្រឹក្ស និមន្តចូលរួមប្រជុំដើម្បីជាទីប្រឹក្សា ។ អង្គប្រជុំដ៏សម្ងាត់នេះ បានសំរេចមាគ៌ារបស់យើងដូចតទៅនេះ ៖

១— ជៀសវាងជាដាច់ខាត កុំបង្ករឿងមុន

២— ធ្វើគ្រប់ឱកាសល្អ ដើម្បីធ្វើឱ្យគេអាណិតយើង

៣— ប៉ុន្តែអ្វីដែលយើងមិនព្រមទទួល គឺកំហុសដែលគេដាក់មកលើយើង ដោយគំនិតប៉ុន្មានថ្ងៃមុននេះ គេចោទថា យើងនាំគ្នាបះបោរប្រឆាំងនឹងវៀតមិញ ដើម្បីឱ្យបារាំងចូលមកត្រួតត្រាបានស្រួល ។ មានជួនកាលគេឱ្យគ្នាគេមកនិយាយករយើងថា គេអាណាស់ប្រសិនបើបងប្អូនខ្មែរយកដីកម្ពុជាក្រោមឱ្យខ្មែរភ្នំពេញត្រួតត្រាវិញ គឺព្រោះស្រួល « រកស៊ី »... ។

ដោយមានជំនឿទៅលើព្រះពុទ្ធសាសនាដ៏មោះមុតផង ដើម្បីលើកទឹកចិត្តអ្នកតស៊ូរបស់យើងផង យើងក៏បានបួលគម្ពីរ "បាក់គម្ពីរ" យើញត្រង់សុរគត ជាអ្នកគោរពព្រះសមណគោត្តម និងករហាចិន ជាអ្នកគោរពពួកព្រាហ្មណ៍នៅក្នុងលិង្គកលដែល ករហាចិនប្រើដើម្បីធ្វើគុតព្រះពុទ្ធនេះបានផលជុំយទៅវិញ រួមសេចក្តីមកថា ការតស៊ូរបស់យើងមុខតែនឹងជោគជ័យ ។

សូមជំរាបអស់លោកអ្នកអានថា ការដែលមានរឿងទាក់ទង

ទីងព្រះសង្ឃ មកដល់ពេលយើងរៀបចំផ្លូវជីរាបទាងលើ គាតស្ងប់ស្ងាត់ផ្លូវជាមានឡើងវិញដែរ ។ ស្រាប់តែរវាង ថ្ងៃ ៣០ ធ្នូ ១៩៤៥ មានយួនមួយក្រុមប្រហែល ១០០ ពួយនាក់ ចូលពីកោះកុងជីមមកទៀត មកឡោមព័ទ្ធ ភូមិបង-ប្អូនយើងនៅភូនក្រែកបំរុងសាងវិនាសកម្ម ។ ប៉ុន្តែ បង-ប្អូនយើងបានប្រមូលគ្នាប្រយុទ្ធជាមួយខ្មាំងយួន មាន កាំភ្លើងបាញ់សត្វ៦ ដើម ក្រៅពីធ្នូ-ស្នា ខ្មែរយើងគ្មានអាវុធ អ្វីក្រៅពីកាំបិត-ដាវ-លំពែង ដូចនេះខ្មែរយើងត្រូវប្រើតាំង តែពីអំបែងពាង-ដប-ដុំអិដ្ឋ ត្រូវតែទៅរកយួនតាំងពីព្រឹក ទាងអាយតាំងពីម៉ោង ១៦ រហូតដល់ម៉ោង ១៧ ។ នៅ ម៉ោងនេះ ខ្មែរយើងមួយក្រុមបានបញ្ឆោតខ្មាំង ហើយលប ចូលព្រៃកទៅប្រឡុកជាមួយ ធ្វើឲ្យយួនបាក់ទ័ព ។ ថ្ងៃនោះ យើងស្លាប់ ២ នាក់ យួនស្លាប់ប្រហែល ៦ នាក់ ។

ចំពោះព្រឹត្តិហេតុថ្មីនេះ យើងលែងសង្ស័យអ្វីទៀតចំពោះពាក្យផ្អែមល្ហែមដូចជីរាបទាងលើនេះទៀតហើយ ។ ប៉ុន្តែ យើងក៏ឥតមានផ្ដើមធាកប្រយុទ្ធអ្វីជាថ្មីទៀតដែរ ។ ហើយយើងមានការប្រុងប្រយ័ត្នខ្ពស់ មួយជាដប់ ។

ដើម្បីជាការងាយស្រួលក្នុងការតស៊ូរបស់យើង យើងបានតាំងសេនាធិការដ្ឋានរបស់យើងនៅផ្ទះលោកតា អគីត ហៅសង្កាត់ ឡូរ៉ំ ឈើន ស្ថិតនៅក្រោយសាលាសង្កាត់ព្រែក

គយ ៗ បានជាយើងយកកន្លែងនេះ ធ្វើជាកន្លែងចាត់ការរបស់យើងដោយសារកន្លែងនេះមានស្ពានមួយ ដែលយើងត្រូវការពារ ហើយជាកន្លែងដែលព្រែកបែកជាបី ៖ មួយទៅបឹងត្រលិត-ដងក្តាន់-ដើមពោធិ-ភូនក្អក- មួយទៀតទៅខាងកើត-ទៅភូមិកំបុត-ព្រែកទីបី បែកទៅរកផ្សារព្រែកគយទៅផែនង- ចាក់ទូង- បាយតៅ និងទីរួមខេត្តឃ្លាំង ពោលគឺជាចំណុចមួយសំខាន់ខាងផ្នែកយុទ្ធសាស្ត្រ ៗ

បើគេឈរលើស្ពាន មើលទៅទិសខាងត្បូង គេនឹងឃើញវាលស្រែល្វឹងល្វើយជាប់កន្ទុយភ្នែកចំនួនរាប់ម៉ឺនហិកតា នៅចំហៀងខាងស្តាំវាលនេះ មានព្រែកមួយ ហៅព្រែកបឹងត្រលិត ៗ បង-ប្អូនយើងបានតាំងលំនៅផ្ទះ នៅតាមមាត់ព្រែកខាងខ្នងនៃ រីឯពលរដ្ឋយួននៅក្រោយខាងស្តាំ ៗ នៅចុងព្រែកខាងជើង មានវត្តខ្មែរមួយ ហៅថាវត្តភូនក្អក ដែលស្ថិតនៅមិនឆ្ងាយប៉ុន្មានពីផ្សារភូនក្អក ៗ ចម្ងាយពីស្ពានវត្តភូនក្អក ប្រហែល ១០ គ.ម ប៉ុណ្ណោះ ៗ ភូមិបង ប្អូនយើងនៅទីនោះ សុទ្ធសឹងជាភូមិស្តុកស្តម្ភ មានដើមដូង-ស្លា-សន្តិ-អំពៅ- ស្ពៃ-ស្តៅ- ចេក-ស្វាយ ដុះពាសពេញ ជាទីសែនមនោរម្យ ៗ

វេលាថ្ងៃទី ២ មករា ១៩៤៦ ពេលដែលសមាជិកសេនាធិការស្រស់ស្រូបរួចផ្ទះរៀងរាល់ថ្ងៃដែរ យើងតែងទៅ

ដែលគេលើកទឹកចិត្ត បង ប្អូនយើង ដែលយាមនៅលើស្ពាន ដើម្បីបំភ្លេចកិច្ចកង្វល់ទាំងឡាយ ។ មួយសន្ទុះក្រោយមក វេលាម៉ោង ៧ កន្លះ ពួកយើងបានទាញអារម្មណ៍យើងឲ្យផ្ដោតទៅលើដុំផ្សែង ដែលហុយខ្ពោលទៅលើមេឃ នៅម្ដុំវត្តភូនក្លក ហើយដុំផ្សែងដទៃទៀត បានហុយឡើងបន្តបន្ទាប់គ្នា ដែលញាំងឲ្យយើងដឹងថា វិនាសកម្ម បានធ្លាក់មកលើបង ប្អូនយើងទៀតហើយ ។ ពេលជាមួយគ្នានោះ អ្នកនាំសារក៏បំផាយសេះមកដល់ ហើយប្រាប់ថាយួនប្រហែល ១០០ បាយនាក់ ខ្លះជិះទូក ខ្លះដើរ បានចូលមកដុតវត្តជើងក្លក និងដុតផ្ទះ បង ប្អូនយើងអស់ជាច្រើនខ្នង ។ អ្នកនាំសារបានបញ្ជាក់ទៀតថា ៖ ទូកយួន ដែលមានយួន ប្រដាប់អាវុធជិះក្នុងនោះ បានបើកចូលក្នុងព្រែកបឹងព្រលិត បណ្ដើរ បាញ់បណ្ដើរ ធ្វើឲ្យបង ប្អូនយើងភៀសចេញពីភូមិ ដើម្បីទុកឲ្យគ្នាវាដើរដុតផ្ទះតាមក្រោយ ។ និងគ្នាវាមួយចំនួនទៀត តាមជួយការពារផ្ទះយួន ដែលសង់តាមមាត់ព្រែកទាំងស្ដាំ ជួចដំរាបទាំងលើ ។

ក្រោយពីបានឮស្នូរស្គរដំជាកេតសញ្ញាមក បងប្អូនយើងប្រហែល ២០០ នាក់ បានមកដល់មុខគេ ប្រដាប់ដោយ ដាវ-ស្នា-លំពែង-ក្បូក-កាំបិតដងវែងនៅនិងដៃស្រាប់ ។ ក្រោយពីយុទ្ធជនយើងដឹងច្បាស់នូវស្ថានការណ៍

និងវិធីម្ចាប់ខ្មាំងមក និងដោយសារសំណាមតាដោយទទួល ពីតាត់ផង យើងក៏បានប្រគល់ភារៈដឹកនាំទ័ពជូនលោកតា-ឡាំ ណុប «អាយុ ៥០ ឆ្នាំ» ។

គឺនៅពេលនេះហើយដែលបង - ប្អូនយើងបានឃើញ ទង់ជាតិរូបប្រាសាទជាលើកទីមួយ ដែលសេនាធិការយើង ទើបនឹងធ្វើរួច ហើយប្រគល់ជូនលោកតា ណុប លើកទ័ព ទៅរកខ្មាំង ។

ក្រោយតែប្រហែលមួយម៉ោង ពីទ័ពយើងចេញដំណើរ ទៅ ភ្លើងដែលនេះតែកិលជីកយកកាំនោះ ក៏នេះផ្ទុះទៅវិញ ដែលជាហេតុប្រាប់ឱ្យយើងដឹងថា ខ្មាំងមានជោគជ័យហើយ ដោយគេបានដុតផ្ទះយួន ដែលរាយតាមមាត់ព្រែកទាង ស្ពាននោះម្តងវិញ ។

សូមបញ្ជាក់ថា ក្រោយពីទ័ពយើងចូលទៅដល់ យើង គ្រាន់តែចែកគ្នាឱ្យទប់ទល់ខ្មាំងបន្តិចបន្តួច ដើម្បីឱ្យយួននិង យើងដាច់ដៃគ្នាសិន ហើយយើងចាត់ឱ្យគ្នាយើងមួយពួក ទៀត កាប់ដើមឈើដែលដុះតាមមាត់ព្រែកស្រាប់នោះ រំលំ ទទឹងព្រែកដើម្បីឃាំងទូកយួន កុំឱ្យរត់ធ្វើចលនាទៀតកើត និងបង្ខំយួនដែលនៅក្នុងទូកនោះឱ្យឡើងគោកផង ដើម្បីកំ ទេចក់ជាក្រោយ ។ ហេតុដូចនេះហើយបានជានៅពេល ដែលទឹកនាច ថ្ងៃទឹកស្រកចុះច្រើន ខ្មាំងនៅក្នុងទូកដែល

ត្រូវមាត់ច្រាំងព្រែកបាំងក្អែក មើលមកយើងមិនឃើញ បាន
ឧកាសល្អញាំងយើងឲ្យលួចទៅផឹកទូកបាន ហើយគប់ទូក
នោះមិនជុំឈើ-ជុំដី-គ្រាប់បែកស៊ីម៉ង់ត៍ ។ យួនទ្រាំមិនបាន
ក៏រត់ចោលទូក គឺនៅពេលនោះហើយដែលទាក់ប្រយុទ្ធដ៏
សាហាវរវាងខ្មែរ និង យួនបានកើតឡើង ។ នៅពេលវាបាក់
ទ័ព យុទ្ធជនយើងបានដេញកាប់សត្រូវទាំងស្រស់ ដេញ
ប្រហែល ២គម. យួនអស់គ្រាប់ ខ្មែរដេញយួនរហូតផ្សារ
កូនក្អែក ចម្ងាយពីកន្លែងប្រយុទ្ធដំបូងប្រហែល ៤គម. ។
ត្រង់នេះយើងសូមបើកវង់ក្រចក ដើម្បីសំដែងសេចក្តីសោក
ស្តាយ ដោយយុទ្ធជនដ៏ក្លង់ខ្ញុំម្នាក់ឈ្មោះ ថាច់ វង់ ត្រូវជា
ក្មួយលោកតា ថាច់ ពេជ ដែលត្រូវរបួសនៅក្រោយផ្សារ
កូនក្អែក ហើយត្រូវយួនអារកបាន ដោយគ្នាយើងរត់ទៅ
ជួយមិនទាន់ ។

នៅពេលដែលទ័ពយើងត្រឡប់មកវិញ ដំណឹងពីយួន
ផុតវត្តកូនក្អែក បានហិចហើរលាន់ឮរន្ធឺទៅគ្រប់ទិសទី ដូច
ស្នូរផ្គរលាន់ ។ នេះជាកំហុសមួយធំ ក្រៃណាស់ ដែលយួន
បានប្រព្រឹត្តមកលើខ្មែរ មកលើសាសនាដែលខ្មែរទូទៅ
គោរព ។ ផ្ទះខ្មែរនេះ ខ្មែរឥតគិតទេ ប៉ុន្តែអ្វីដែលខ្មែរ
គោរព ហើយត្រូវគេធ្វើឲ្យអប្បរស្មី ខ្មែរឈឺចាប់រកទីបំផុត
គ្មាន ។

ដោយសារវត្តកូនក្រុកត្រូវបំផ្លាញ ខ្មែរ និង យួន បើកទាក ប្រយុទ្ធកាប់សម្លាប់គ្នាសឹងគ្រប់ទិសទី សាយភាយរហូតទៅ ដល់ទីប្រជុំជន បាយនៅ-ចាក់ទ្រឹង ។ល។ ដែលនៅឆ្ងាយពី ព្រែកគយប្រហែល ២០ គ.ម ។ នៅស្រុកខ្លះនៃខេត្តពល លាវ ក៏ដូចនេះដែរ ។ ខ្មែរ និងយួន បានចោទគ្នាទៅវិញ ទៅមកតែអ្វីដែលយួនមិនព្រមរក គឺឫសគល់ គឺប្រភព គឺ មេក្លើងដែលញុាំងខ្មែរ និងយួនឲ្យនិយាយស្តាប់គ្នាលែងបាន ដូចបុរាណលោកប្រៀបទៅដើមចេក និងក្របីជ្លូខ្ទោះឯង ។

ហេតុដូចនេះហើយទើបរៀងរាល់ថ្ងៃ គេតែងឃើញ អត្តឃាតគ្រប់ទិសទី ។ ឯនេះខ្មែរដុតផ្ទះយួន ។ ឯនោះយួន បំផ្លាញសេហដ្ឋានខ្មែរ ។ នៅតាមព្រែក ពីព្រែកគយ ទៅ បាយនៅ បណ្តោយប្រហែល ២០ គ-ម ប៉ុណ្ណោះ គេ ឃើញមានសាកសពខ្មែរ និងយួន អណ្តែតដូចរណែលរាប់ រយ ។ នៅតាមព្រែកដទៃទៀត ក៏មិនខុសគ្នាប៉ុន្មានពីព្រែក នេះដែរ ។ អ្នកស្រុកមិនហ៊ានទទួលទានទឹក តមមិនយក អន្ទង់-បង្កង-បង្គា-ត្រី-ក្តាមសមុទ្រ ។ល។ ធ្វើអាហារទេ ។

ក្រុមយើងតែងលើកគ្នាទៅជួយនៅកន្លែងណាដែលត្រូវ ការ ។

សូមជំរាបថា មកដល់ពេលនេះ យើងមានតែកាំបិត-ពូថៅ ដើម្បីការពារខ្លួន ។ ប៉ុន្តែអ្វីដែលជាកម្លាំងកំពូល

របស់យើង គឺជំនឿលើខ្លួនឯង លើការរួបរួមគ្នា លើការចេះស្តាប់គ្នា ចេះគោរពបទបញ្ជា មានវិន័យថ្លៃថ្នូរ ។ ឧទាហរណ៍ ពេលប្រុស ៗ ទៅប្រចាំការនៅសេនាធិការដ្ឋានដែលមានចំនួនរាប់ពាន់នាក់រៀងរាល់ថ្ងៃ ស្រី ៗ ណាដែលលែទៅបាន ៗ ទៅជួយរៀបចំបាយទឹក ជូនយុទ្ធជនគ្រប់ពេលវេលា ។ ពិតមែនតែយើងគ្មានប្រាក់សំរាប់ចំណាយ ប៉ុន្តែបាយ ម្ហូប មិនចេះខ្វះ ពីព្រោះម្នាក់ ៗ ដែលអញ្ជើញមករួបរួមកម្លាំងគ្នានោះក្នុងឋានៈជាយុទ្ធជនក្តី ជាអ្នកមានមុខការផ្សេង ពីនេះទៀតក្តី មិនដែលអញ្ជើញមកដៃទទេទេ ។ អ្នកក្រីក្រក៏សុខចិត្តចូលរួមក្នុងការប្រយុទ្ធជួយគ្នា ជាពិសេសពូ ៗ ដែលមាន វ័យចាស់ទៅហើយ ក៏បានមកជួយរែកទឹក ពុះឧសបិតចង្កេះ លើកដាក់របស់របរផ្សេង ៗ ។ ក្រៅពីជំនឿលើខ្លួនឯង យើងមានជំនឿទៅលើព្រះពុទ្ធសាសនាមុតមាំណាស់ ។ ហេតុដូចនេះហើយ បានជានៅពេលមុនចេញទៅបំពេញសកម្មភាពម្តង ៗ អ្នកដែលចេះធម៌ព្រះពុទ្ធតែងសូត្រប្រក់ព្រុំជូនដល់យុទ្ធជនយើង «អស់ទឹកទាំងពាង» ធម៌ដែលយកមកប្រើ គឺធម៌ឥតិបិសោ ..... ។

កាំភ្លើងដែលយើងយកបានពីខ្មាំងបីដើម មានមួយដើមបាក់ពេលប្រយុទ្ធគ្នា ពីរដើមទៀតជាកាំភ្លើងប្រមាញ់ យើងទុកសម្រាប់តែបាញ់ពេលដោះកុម្មង់ ៗ ឬ បាញ់សំឡុត

សត្រូវព្រោះមិនសូវមានគ្រាប់ ។ ហើយកាលនោះ នៅពេលប្រយុទ្ធគ្នាម្ដងៗ យួនក៏ពុំសូវមានអាវុធអ្វីក្រៅពីមុស្កេតុង កាំភ្លើងប្រមាញ់ និងព្រួញ-ស្នា កាំបិតស្នៀត ដែលយួនហៅថា កាំបិត " យួគិប " ខុសគ្នាពីខ្មែរយើងដែលប្រើតែព្រនង់មានកាំបិតខាងចុងម្ខាងជាប់ - លំពែង - កាំបិតវែង-ស្ន-ឡុក និងកាំបិតយួគិបដែរ គ្រាប់បែកដៃធ្វើពីស៊ីម៉ងត៍មានបន្ទាដែកគោល យើងធ្វើបានខ្លះទុកប្រើការពេលប្រឡូកគ្នាៗ កាំភ្លើងអាយ ដែលគេធ្វើដោយអារត្បូកធំនោះ យើងធ្វើសម្រាប់តែយកស្នូរ ឲ្យតែប៉ុណ្ណោះ «ដូចយៀកកុងភាយធ្វើតដែរ» ។

ការមានរបៀបលើសត្រូវ ដែលនាំឲ្យយើងរួចពីស្លាប់ រហូតមកដល់ពេលនេះ គឺស្ថិតនៅលើវីរៈភាពដែលបងប្អូនយើងមាន ៗ អ្នកដឹកនាំទ័ព ទោះចាស់ក្ដី ក្មេងក្ដី ច្រើនតែជាអ្នកហ៊ាំសាហួន រីឯយុទ្ធជនទៀតសោត មានការឆ្លាតវាងវៃហួសពីការស្មាន ។

ដូចនេះអ្វីដែលយើងនៅខ្វះ គឺខ្វះសេចក្ដីសង្ឃឹមទៅលើអាគតរបស់យើង បើយើងហើយនៅចាំតែរង់ដូចនេះតទៅទៀតមិនបង្ហាញឲ្យសត្រូវរបស់យើងឃើញ ស ឃើញខ្មៅម្ដងទេ ។